# សុន្ទរកថាស្វាគមន៍

## ថ្លែងដោយ បណ្ឌិត កៅ គឹមហួន ប្រធានសាកលវិទ្យាល័យកម្ពុជា

## ក្នុងពិធី

## ប្រគល់បំណ្ណជ័យលាភីអាហារូបករណ៍

## សម្តេចតេជោ ហ៊ុន សែន ចក្ខុវិស័យ ១០០

## វិទ្យាស្ថានជាតិអប់រំ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨

**សូមគោរព:**

- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- លោកបណ្ឌិត **Rikhi Thakral** ប្រធានក្រុមហ៊ុន **Thakral Group of Companies** នៃ សាធារណរដ្ឋសឹង្ហបុរី និង គណៈប្រតិភូធុរៈកិច្ច ជាន់ខ្ពស់របស់លោក ជាទីគោរព !
- ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ជាភ្ញៀវកិត្តិយស និង ប្អូនៗជានិស្សិត ទាំងអស់ ជាទីគោរព !

ជាបឋម ក្នុងនាមក្រុមប្រឹក្សាភិបាល គណៈសាស្ត្រាចារ្យ និង មន្ត្រីបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យកម្ពុជា ខ្ញុំសូមសម្តែងនូវសេចក្តីដឹងគុណដ៏ជ្រាលជ្រៅ ចំពោះអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវ** ក្នុងពិធីប្រគល់ប័ណ្ណ " **អាហារូបករណ៍សម្តេចតេជោ ហ៊ុន សែន ចក្ខុវិស័យ ១០០** " ជាលើកដំបូងនៅព្រះរាជាណាចក្រកម្ពុជា ។ វត្តមានដែលប្រកបដោយមោទនភាពរបស់ សម្តេច គឺជាការឆ្លុះបញ្ចាំងឱ្យឃើញនូវការយកចិត្តទុកដាក់របស់ សម្តេចនាយក ចំពោះសិស្សានុសិស្សក្រីក្រនៅទូទាំងប្រទេសអោយបានបន្តការសិក្សាទៅថ្នាក់ឧត្តម ដើម្បីក្រេបជញ្ជក់យកចំណេះវិជ្ជា អោយក្លាយទៅជាពលរដ្ឋល្អ ជាទំពាំងស្នងឫស្សី ជាសសរទ្រូង និងជាកម្លាំងស្នាបនិកដ៏រឹងមាំរបស់ប្រទេសជាតិ និង ប្រជាជនកម្ពុជា ។

ម្យ៉ាងវិញទៀត សាកលវិទ្យាល័យកម្ពុជា សូមថ្លែងអំណរគុណដ៏ស្មោះចំពោះ **លោបណ្ឌិត** Rikhi Thakral ប្រធានក្រុមហ៊ុន Thakral Group of Companies នៃប្រទេសសឹង្ហបុរី ព្រមទាំងក្រុមគ្រួសារ និងគណៈប្រតិភូជាន់ខ្ពស់របស់លោក ដែលបានជួយឧបត្ថម្ភនូវ " **អាហារូបករណ៍ សម្តេចតេជោ ហ៊ុន សែន ចក្ខុវិស័យ ១០០** " និង អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់ប័ណ្ណអាហារូបករណ៏ដ៏មានសារៈសំខាន់នេះ ។

សាកលវិទ្យាល័យកម្ពុជា ក៏សូមឆ្លៀតឱកាសនេះផងដែរ ដើម្បីថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះវត្តមានរបស់ **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ — ជាមាតាបិតា និង អាណាព្យាបាលសិស្ស** ក៏ដូចជាប្អូនៗជាសិស្សានុសិស្សឆ្នើម ដែលបានប្រឡងជាប់ **អាហារូបករណ៍ សម្តេចតេជោ ហ៊ុន សែន ចក្ខុវិស័យ** ១០០ ជំនាន់ទី១ នេះ ។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និង លោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់ ! គណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី... !**

ព្រឹកនេះ សាកលវិទ្យាល័យកម្ពុជាមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និង ក្តីរំភើបរីករាយ ដោយបានរៀបចំពិធីប្រគល់ប័ណ្ណ **អាហារូបករណ៍ សម្តេចតេជោ ហ៊ុន សែន ចក្ខុវិស័យ ១០០** ជូនសិស្សានុសិស្សឆ្នើម ចំនួន ១០០ នាក់ បន្ទាប់ពីបានធ្វើការប្រឡង ចម្រាញ់ - ជម្រើស និង ជម្រុះ ក្នុងចំណោមសិស្សដែលបានទទួលនិទ្ទេស A, B, C និង D ក្នុងសម័យប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទូទាំងប្រទេស ដែលមានចំនួន **៣,៥៤៨ នាក់ ក្នុងនោះមានបេក្ខជនចំនួន ១,៩២៧ នាក់ ហើយនឹង បេក្ខនារីចំនួន ១,៦២១ នាក់ កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៨ កន្លងទៅនេះ** ។ សិស្សទាំង ១០០ **នាក់នោះ ( មានបេក្ខជនចំនួន ៧៤ នាក់ និង បេក្ខនារីចំនួន ២៦ នាក់)** ។ សិស្សទាំង ១០០ នាក់នេះ គឺជាសិស្សឆ្នើមដែលត្រូវចូលសិក្សាយកសញ្ញាបត្រថ្នាក់បរិញ្ញា លើ (មុខវិជ្ជា) ឯកទេសមួយចំនួន នៅសាកលវិទ្យាល័យកម្ពុជា សំរាប់រយៈពេល ៤ឆ្នាំ (គិតពីឆ្នាំ ២០០៨ ដល់ ២០១២) តាមរយៈការទទួលយកអាហារូបករណ៍ **សម្តេចតេជោ ហ៊ុន សែន ចក្ខុវិស័យ ១០០** ដែលឧបត្ថម្ភដោយ លោកបណ្ឌិត **Rikhi Thakral** នាយកប្រតិបត្តិ ក្រុមហ៊ុន Thakral Group of Companies នៃសាធារណរដ្ឋ សឹង្ហបុរី និង ក្រុមគ្រួសារ ព្រមទាំងសហការីរបស់លោក ។

ជាគោលដៅទៅអនាគត ប្អូនៗនិស្សិតឆ្នើមទាំង **១០០ នាក់នេះ** តាមរយៈភាពពូកែរបស់គេ និងតាមកម្មវិធីសិក្សាប្រកបដោយគុណភាពរបស់ សាកលវិទ្យាល័យកម្ពុជា នឹងក្លាយខ្លួនជាបញ្ញវន្តថ្មី ប្រកបដោយសមត្ថភាព យល់ដឹងនិងមនសិការ វិជ្ជាជីវៈ និងជាអ្នកដឹកនាំវ័យក្មេងទៅអនាគត ។ យ៉ាងហោចណាស់ក៏ ២០% នៃនិស្សិតទាំងនេះ នឹងក្លាយជាប្រធានអង្គភាព ប្រធានការិយាល័យ ប្រធានផ្នែកបច្ចេកវិទ្យាព័ត៌មាន ប្រធានស្ថាប័នអប់រំ និងជាប្រធានអង្គការរដ្ឋ និងឯកជននានា។ ៣០%នឹងក្លាយជាអ្នកផលិតការងារជូនសហគមន៍ និង ៥០%ទៀតជាកម្លាំងផលិតរបស់សង្គមជាតិយើង។ ផលិតផលជាធនធាន មនុស្សថ្មីទាំងនេះ គឺជាកម្លាំងស្ថាបនា— ការពារ និង អភិវឌ្ឍន៍ជាតិយើងដ៏រឹងមាំទៅអនាគត ។

**សម្តេចតេជោ និង លោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

**ភ្ញៀវកិត្តិយសជាតិ , អន្តរជាតិ និង ក្មួយៗជានិស្សិត !**

ពិធីប្រគល់ប័ណ្ណអាហារូបករណ៍នេះ គឺជា " **ឱកាសមាស** " ដើម្បីឱ្យប្អូនៗបានស្តាប់នូវមតិណែនាំដ៏មានតម្លៃបំផុតរបស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី ដែលជាពហុសូត្រ ប្រកបដោយទេព្យកោសល្យលើគ្រប់មុខវិជ្ជា ។ ការបានជួប **សម្តេចនាយក** ដើម្បីបានត្រង់ត្រាប់នូវឱវាទល្អៗ សំរាប់ការសិក្សាថ្នាក់ឧត្តម គឺជាឱកាសដ៏កម្រណាស់ ដូច្នេះស្នើសុំប្អូនៗទាំងអស់ ខិតខំយកចិត្តទុកដាក់ស្តាប់ - ត្រិះរិះពិចារណា និង កត់ត្រាទុកនូវឱវាទល្អៗ ដែល **សម្តេចនាយក** និងមានមតិក្នុងពេលបន្តិចទៀតនេះ ដើម្បីបានជាគតិ និង ជាប្រទីបបំភ្លឺផ្លូវអោយប្អូនៗ ចាប់ផ្តើមសិក្សានៅថ្នាក់សាកលវិទ្យាល័យបានជោគជ័យ ។

នៅទីបញ្ចប់នេះ ក្នុងនាមសាកលវិទ្យាល័យកម្ពុជា ខ្ញុំបាទសូមសម្តែងជាថ្មី នូវសេចក្តីដឹងគុណដ៏ជ្រាលជ្រៅចំពោះអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចនាយករដ្ឋមន្ត្រី និង លោកជំទាវ** ក្នុងពិធីប្រគល់ប័ណ្ណ **អាហារូបករណ៍ សម្តេចតេជោ ចក្ខុវិស័យ ១០០** ជាប្រវត្តិសាស្ត្រនេះ ។

សូមថ្លែងអំណរគុណចំពោះ គណៈអធិបតី ព្រមទាំង ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាពិសេសគឺ លោកបណ្ឌិត **Rikhi Thakral** នឹងទាំងគណៈប្រតិភូ ដែលបានអញ្ជើញចូលរួមក្នុងពិធីដ៏មហោឡារិកនេះ ។

សូមគោរពជូនពរ **សម្តេចនាយក និង លោកជំទាវ** ព្រមទាំង គណៈអធិបតី ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ អស់លោក លោកស្រី និង ប្អូនៗជានិស្សិតអាហារូបករណ៍ថ្មី សូមឱ្យបានប្រកបដោយ **សុខុមាលភាពល្អ កម្លាំងពលំមាំមួន ប្រាជ្ញាឈ្លាសវៃ ក្នុងមហាជ័យជំនះ និង ការអភិវឌ្ឍន៍** ។

**សូមអរគុណ !**